**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៤/០១៣ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងអាស៊ានស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី០១ ខែមិនា ឆ្នាំ២០០៦ ស្តីពីកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ
- បានឃើញកិច្ចព្រមព្រៀងស្តីពីការបង្កើតនិងអនុវត្តបញ្ជរតែមួយអាស៊ាន ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៥ នៅទីក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ត្រូវបានបង្កើត "**គណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ**" ហៅកាត់ថា "**គ.ដ.ប.ជ**" ដើម្បីគ្រប់គ្រងការអភិវឌ្ឍ និងអនុវត្តគម្រោងបញ្ជរតែមួយជាតិ។

**គ.ដ.ប.ជ** ត្រូវមានលេខាធិការដ្ឋាននៅអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រាប់បម្រើការងាររបស់ខ្លួន។ ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន **គ.ដ.ប.ជ** ត្រូវកំណត់ដោយប្រធាន **គ.ដ.ប.ជ**។

## ជំពូកទី២

## សមាសភាពនិងរចនាសម្ព័ន្ធ

**មាត្រា២.-**

**គ.ដ.ប.ជ** មានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១. | រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២. | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣. | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៤. | អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | អនុប្រធានអចិន្ត្រៃយ៍ |
| ៥. | តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៦. | តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៧. | តំណាងក្រសួងឧស្សាហកម្មនិងសិប្បកម្ម | សមាជិក |
| ៨. | តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៩. | តំណាងក្រសួងសុខាភិបាល | សមាជិក |
| ១០. | តំណាងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| ១១. | តំណាងធនាគារជាតិនៃកម្ពុជា | សមាជិក |
| ១២. | តំណាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |
| ១៣. | តំណាងសភាពាណិជ្ជកម្មកម្ពុជា | សមាជិក |
| ១៤. | តំណាងអាជ្ញាធរកំពង់ផែស្វយ័តក្រុងព្រះសីហនុ | សមាជិក |
| ១៥. | តំណាងអាជ្ញាធរអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ | សមាជិក |

| | | |
|---|---|---|
| ១៦. | តំណាងអាជ្ញាធរកំពង់ផែស្វយ័តភ្នំពេញ | សមាជិក |
| ១៧. | តំណាងសមាគមដឹកជញ្ជូនទំនិញផ្លូវគោកកម្ពុជា | សមាជិក |
| ១៨. | តំណាងសមាគមអ្នកបញ្ជូនទំនិញកម្ពុជា | សមាជិក |
| ១៩. | តំណាងសមាគមជើងសាគយ | សមាជិក |

**មាត្រា៣.-**

គ.ជ.ប.ជ ត្រូវបង្កើតក្រុមជំនាញ ដូចខាងក្រោម ៖

១. ក្រុមផ្តល់ប្រឹក្សាផ្នែកច្បាប់និងគោលនយោបាយគម្រោងបញ្ជរតែមួយជាតិ ។

២. ក្រុមអនុវត្តគម្រោងបញ្ជរតែមួយជាតិ ។

៣. ក្រុមការងារផ្សេងទៀត តាមការចាំបាច់។

## ជំពូកទី៣

## តួនាទីនិងភារកិច្ចរបស់ គ.ជ.ប.ជ

**មាត្រា៤.-**

គ.ជ.ប.ជ មានតួនាទីនិងភារកិច្ចដូចខាងក្រោម ៖

- បំពេញមុខងារជាសេនាធិការឱ្យរាជរដ្ឋាភិបាល លើបេសកកម្មដឹកនាំ គ្រប់គ្រងការអភិវឌ្ឍ និងអនុវត្តបញ្ជរតែមួយជាតិ រាប់បញ្ចូលទាំងការតភ្ជាប់បញ្ជរតែមួយជាតិទៅបញ្ជរតែមួយអាស៊ានផង ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា
- រៀបចំគសាងទស្សនទាន ចក្ខុវិស័យ ក្របខ័ណ្ឌច្បាប់ និងផែនការយុទ្ធសាស្ត្រអនុវត្តគម្រោងបញ្ជរតែមួយជាតិ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា
- គ្រប់គ្រងនិងត្រួតពិនិត្យការប្រើប្រាស់ថវិកាគម្រោង រាប់បញ្ចូលទាំងការពិនិត្យនិងអនុម័តលទ្ធកម្មគម្រោង ដើម្បីធានាបាននូវការប្រើប្រាស់មូលនិធិគម្រោងត្រឹមត្រូវ
- ពិនិត្យនិងអនុម័តផែនការសកម្មភាព និងអនុសាសន៍ ដែលស្នើដោយក្រុមផ្តល់ប្រឹក្សាផ្នែកច្បាប់និងគោលនយោបាយ និងក្រុមអនុវត្តគម្រោងបញ្ជរតែមួយជាតិ
- តាមដានសកម្មភាព និងវាយតម្លៃពីវឌ្ឍនភាពនៃការអភិវឌ្ឍ និងអនុវត្តគម្រោង
- ពិនិត្យ និងវាយតម្លៃលើសកម្មភាពចូលរួមអនុវត្តគម្រោងរបស់បណ្តាក្រសួង ស្ថាប័នជំនាញ និងវិស័យឯកជនពាក់ព័ន្ធ
- កំណត់កម្រៃសេវាប្រើប្រាស់បញ្ជរតែមួយជាតិ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា

- កែសម្រួល និង/ឬបំពេញបន្ថែមសមាសភាពគ.ជ.ម.ជ តាមការចាំបាច់
- ពិនិត្យ និងផ្តល់អនុសាសន៍លើការបង្កើតក្រុមការងារអភិវឌ្ឍនិងអនុវត្តប្រព័ន្ធស្វ័យប្រវត្តិកម្មតាមក្រសួង ស្ថាប័នជំនាញ និងសម្រាប់ប្រតិបត្តិការតភ្ជាប់ជាមួយបញ្ជរតែមួយជាតិ
- ស្វែងរកប្រភពថវិកាពីដៃគូអភិវឌ្ឍន៍នានាសម្រាប់ការអភិវឌ្ឍនិងអនុវត្តគម្រោងបញ្ជរតែមួយជាតិ
- ធ្វើរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តគម្រោងបញ្ជរតែមួយជាតិ ជូនរាជរដ្ឋាភិបាលកម្ពុជា
- អនុវត្តភារកិច្ចផ្សេងទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន ។

## ជំពូកទី៤

## ការប្រព្រឹត្តទៅរបស់ គ.ជ.ម.ជ

**មាត្រា៥.-**

ធ្វើបច្ចុប្បន្នភាពផែនការសកម្មភាពការងារ និងនីតិវិធីប្រតិបត្តិរបស់ខ្លួនតាមការចាំបាច់ ។

**មាត្រា៦.-**

សមាជិកនៃ **គ.ជ.ម.ជ** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

ប្រធាន **គ.ជ.ម.ជ** ត្រូវដឹកនាំអង្គប្រជុំ។ ក្នុងករណីប្រធានអវត្តមាន ឬ មានធុរៈ អនុប្រធានត្រូវដឹកនាំអង្គប្រជុំជំនួស។

ប្រធាន **គ.ជ.ម.ជ** អាចអញ្ជើញអ្នកជំនាញនិងតំណាងក្រសួង ស្ថាប័នដែលមិនមែនជាសមាជិកនៃ **គ.ជ.ម.ជ** ចូលរួមប្រជុំតាមការចាំបាច់។

## ជំពូកទី៥

## ប្រភពធនធាននិងមូលនិធិ

**មាត្រា៧.-**

ការចំណាយសម្រាប់ដំណើរការ**គ.ជ.ម.ជ** និងសម្រាប់អនុវត្តគម្រោងបញ្ជរតែមួយជាតិ ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិក្នុងគម្រោងថវិការបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬថវិកាស្របច្បាប់ដែលបានមកពីប្រភពផ្សេងទៀត។

**គ.ជ.ម.ជ** មានសិទ្ធិទទួល ចាត់ចែង និងប្រើប្រាស់តាមនីតិវិធីច្បាប់ជាធរមាននូវមូលនិធិដែលបានមកពីប្រភពផ្សេងៗទៀតសម្រាប់ដំណើរការការងាររបស់ខ្លួននិងសម្រាប់អនុវត្តគម្រោងបញ្ជរតែមួយជាតិ។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**មាត្រា៨.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ